ការផ្លាស់ប្តូរច្បាប់ស្តីពីបន្ទុកសេវាសាធារណៈ

# សំណួរសួរញឹកញាប់ (FAQ) សម្រាប់សមាជិកសហគមន៍

ក្រសួងសន្តិសុខមាតុភូមិបានចេញផ្សាយការផ្លាស់ប្តូរច្បាប់ស្តីពី**បន្ទុកសេវាសាធារណៈ** ដែលចូលជាធរមាននៅ**ថ្ងៃទី 24 ខែកុម្ភៈ ឆ្នាំ 2020**។ ច្បាប់ថ្មីនេះប៉ះពាល់ដល់ជនអន្តោប្រវេសន៍ស្របច្បាប់ដែលមិនមាន "ប័ណ្ណបៃតង។" ច្បាប់នេះ**<u>មិន</u>**ប៉ះពាល់ដល់ជនអន្តោប្រវេសន៍ទាំងអស់នោះទេ។

**ប្រការសំខាន់៖ សូមកុំលុបឈ្មោះពីកម្មវិធី Medicaid និង SNAP**

ពីព្រោះជនអន្តោប្រវេសន៍ដែលស្ថិតនៅក្នុងកម្មវិធីទាំងនេះ<u>មិន</u>ស្ថិតក្រោមបន្ទុកសេវាសាធារណៈ ឬទទួលបានអត្ថប្រយោជន៍ដែលផ្តល់មូលនិធិពីរដ្ឋប៉ុណ្ណោះ ដែលមិនត្រូវបានរាប់បញ្ចូលក្នុងការធ្វើតេស្តអំពីបន្ទុកសេវាសាធារណៈនោះទេ។

ដូច្នេះសូមកុំលុបឈ្មោះពីកម្មវិធីទាំងនេះដោយមិនបានពិភាក្សាជាមុនជាមួយមេធាវីដែលមានសមត្ថភាព/អ្នកតំណាងដែលមានការយល់ព្រម។ អ្នកអាចរកឃើញបញ្ជីឈ្មោះរបស់ពួកគេនៅទូទាំងប្រទេសនៅលើគេហទំព័រនេះ៖
https://www.immigrationlawhelp.org

## 1. តើបន្ទុកសេវាសាធារណៈជាអ្វី?

នៅពេលជនអន្តោប្រវេសន៍ដាក់ពាក្យសុំ "ប័ណ្ណបៃតង" (ហៅម្យ៉ាងទៀតថាការស្នាក់នៅអចិន្ត្រៃយ៍ ឬ LPR) ឬទិដ្ឋាការដើម្បីចូលសហរដ្ឋអាមេរិក បុគ្គលនោះត្រូវឆ្លងកាត់តេស្តអំពី "បន្ទុកសេវាសាធារណៈ។" តេស្តនេះពិនិត្យមើលថាតើបុគ្គលនោះ (1) ទំនងជាប្រើកម្មវិធីអត្ថប្រយោជន៍សាធារណៈមួយចំនួននាពេលអនាគត (2) ថាតើបុគ្គលនោះបានប្រើប្រាស់កម្មវិធីជាក់លាក់ (3) កាលៈទេសៈរបស់បុគ្គលនោះរួមមានអាយុ ប្រាក់ចំណូល សុខភាព ការអប់រំ ឬជំនាញ (រាប់បញ្ចូលទាំងជំនាញភាសាអង់គ្លេស) និងលិខិតបញ្ជាក់ពីការគាំទ្រពីអ្នកឧបត្ថម្ភរបស់ពួកគេ។

## 2. តើច្បាប់ថ្មីនេះចូលជាធរមាននៅពេលណា?

ច្បាប់ស្តីពីបន្ទុកសាធារណៈចូលជាធរមាននៅ**ថ្ងៃទី 24 ខែកុម្ភៈ ឆ្នាំ 2020** ដែលមានន័យថារាល់ពាក្យសុំដែលបានដាក់ជូននៅថ្ងៃនោះ ឬបន្ទាប់ពីថ្ងៃនោះនឹងត្រូវអនុវត្តតាមច្បាប់ថ្មី។

### 3. តើកម្មវិធីថ្មីមានអ្វីខ្លះដែលនឹងត្រូវពិចារណាសម្រាប់បន្ទុកសេវាសាធារណៈ?

អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ អត្ថប្រយោជន៍ក្រោមបន្ទុកសេវាសាធារណៈកំណត់ជំនួយជាសាច់ប្រាក់ដូចជាជំនួយបណ្ដោះអាសន្នសម្រាប់គ្រួសារខ្វះខាត (TANF) និងប្រាក់ចំណូលសន្តិសុខបន្ថែម (SSI) និងការថែទាំរយៈពេលវែងដែលបង់ប្រាក់ដោយរដ្ឋាភិបាល។ ក្រោមច្បាប់ថ្មី<u>អត្ថប្រយោជន៍ខាងក្រោមនេះ</u>នឹងត្រូវបានពិចារណាឥឡូវនេះ៖

- <u>**Medicaid ផ្តល់មូលនិធិដោយសហព័ន្ធ**</u> (ស្គាល់ថាជា Medi-Cal នៅរដ្ឋកាលីហ្វ័រញ៉ា) *<u>លើកលែងតែ</u>កម្មវិធីទាំងនេះ ៖*
  - o *កម្មវិធី **Medicaid** ផ្តល់មូលនិធិពីរដ្ឋប៉ុណ្ណោះ**
    ***(កម្មវិធីផ្តល់មូលនិធិពីរដ្ឋប៉ុណ្ណោះមិនត្រូវបានពិចារណានៅក្នុងតេស្តបន្ទុកសេវាសាធារណៈទេ)***
  - o *កម្មវិធីសង្គ្រោះបន្ទាន់ Emergency Medicaid/Medi-Cal*
  - o *អត្ថប្រយោជន៍ដែលទទួលបានដោយមនុស្សអាយុក្រោម 21 ឆ្នាំ*
  - o *អត្ថប្រយោជន៍ដែលស្ត្រីទទួលបានក្នុងអំឡុងពេល និង 60 ថ្ងៃក្រោយមានផ្ទៃពោះ*
  - o *សេវាកម្មតាមសាលារៀនសម្រាប់អ្នកទទួលផលនៅក្រោមអាយុចូលរៀនមធ្យមសិក្សា*
  - o *សេវាកម្មដែលផ្តល់មូលនិធិដោយកម្មវិធី Medicaid ប៉ុន្តែផ្តល់ដោយច្បាប់ស្តីពីការអប់រំជនពិការ*
- <u>កម្មវិធីជំនួយអាហារូបត្ថម្ភបន្ថែម</u>* (SNAP, "EBT" ឬ "ប័ណ្ណអាហារ" ដែលគេស្គាល់ថាជាកម្មវិធី CalFresh នៅរដ្ឋកាលីហ្វ័រញ៉ា)
- <u>ជំនួយផ្នែកលំនៅដ្ឋានសាធារណៈរបស់សហព័ន្ធ និងផ្នែកទី 8</u>

** កម្មវិធីមិនមែនជាសាច់ប្រាក់ដែលអ្នកគ្រប់គ្រងរដ្ឋាភិបាលថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋានមិនត្រូវបានចាត់ទុកជាបន្ទុកសេវាសាធារណៈរួមទាំង**កម្មវិធី Medicaid ដែលផ្តល់មូលនិធិដោយរដ្ឋតែប៉ុណ្ណោះ និងកម្មវិធី SNAP។***

### 4. តើមានកត្តាផ្សេងទៀតដែលត្រូវបានចាត់ទុកថាជាបន្ទុកសេវាសាធារណៈដែរឬទេ?

មាន ហើយច្បាប់នេះតម្រូវឱ្យមានការវាយតម្លៃពេញលេញលើកត្តាជាច្រើន ដើម្បីកំណត់ថាតើជនអន្តោប្រវេសន៍ណាម្នាក់នឹងក្លាយជាបន្ទុកសាធារណៈនៅពេលអនាគតដែរឬអត់។ កត្តាទាំងនេះរួមមាន៖ អាយុ ប្រាក់ចំណូល សុខភាព ការអប់រំឬជំនាញ (រួមទាំងជំនាញភាសាអង់គ្លេស) ការប្រើប្រាស់ផលប្រយោជន៍សាធារណៈដែលបានបញ្ជាក់ មានការធានារ៉ាប់រង លិខិតបញ្ជាក់ពីការគាំទ្ររបស់អ្នកឧបត្ថម្ភ។

### 5. តើខ្ញុំឥឡូវនេះគួរឈប់ពីកម្មវិធី Medicaid, SNAP និងកម្មវិធីអត្ថប្រយោជន៍សាធារណៈដទៃទៀតដែរឬទេ?

មិនមែនជនអន្តោប្រវេសន៍ទាំងអស់គឺស្ថិតនៅក្រោមបន្ទុកសេវាសាធារណៈនោះទេ។
ដំបូងអ្នកគួរតែពិនិត្យដើម្បីប្រាកដថាច្បាប់ស្តីពីបន្ទុកសេវាសាធារណៈនេះអនុវត្តចំពោះអ្នក។ សូមមើលលេខ #6 ។
ប្រសិនបើអ្នកត្រូវឆ្លងកាត់តេស្តអំពីបន្ទុកសេវាសាធារណៈ
សូមពិគ្រោះជាមួយមេធាវីដែលមានសមត្ថភាព/អ្នកតំណាងដែលមានការយល់ព្រម។
អ្នកអាចរកឃើញបញ្ជីរបស់ពួកគេនៅទូទាំងប្រទេសនៅលើគេហទំព័រនេះ៖ https://www.immigrationlawhelp.org

សូមចំណាំថា**<u>មិនមែន</u>**រាល់កម្មវិធីអត្ថប្រយោជន៍សាធារណៈសុទ្ធតែត្រូវបានរួមបញ្ចូលនៅក្នុងតេស្តអំពីបន្ទុកសេវាសាធារណៈនោះឡើយ។ វាសំខាន់ណាស់សម្រាប់អ្នកបន្តប្រើប្រាស់កម្មវិធីសំខាន់ៗដូចជាកម្មវិធីខាងក្រោម ដើម្បីថែរក្សាសុខុមាលភាពគ្រួសាររបស់អ្នក៖

- **សុខភាព៖** កម្មវិធី Medicaid (សម្រាប់កុមារ និងស្ត្រីមានមានផ្ទៃពោះ និងកម្មវិធី Medicaid ផ្តល់មូលនិធីពីរដ្ឋប៉ុណ្ណោះ); កម្មវិធី Medicare; កម្មវិធីពិការភាព
- **កម្មវិធីជំនួយអាហារូបត្ថម្ភ៖** WIC; កម្មវិធីអាហារពេលព្រឹកនិងអាហារថ្ងៃត្រង់នៅសាលា
- **សេវាកម្មកុមារ៖** កម្មវិធី Head Start, ការថែទាំកុមារ; ការអប់រំសាធារណៈ
- **សេវាកម្មស្វែងរកការងារ៖** ភាពអត់ការងារធ្វើ សំណងរបស់កម្មករ និងការចូលនិវត្តន៍របស់សហព័ន្ធ និងរដ្ឋ
- **កម្មវិធីមិនមែនសាច់ប្រាក់** ដែលរដ្ឋាភិបាលថ្នាក់រដ្ឋនិងថ្នាក់មូលដ្ឋានគ្រប់គ្រង

### 6. តើច្បាប់នេះមានឥទ្ធិពលលើមនុស្សគ្រប់គ្នាទេ?

ទេ ក្រុមខ្លះ**<u>មិន</u>**ស្ថិតក្រោមបន្ទុកសេវាធារណៈឡើយ។ រួមមានដូចខាងក្រោម៖

- ពលរដ្ឋអាមេរិក
- អ្នករស់នៅអចិន្ត្រៃយ៍ស្របច្បាប់ភាគច្រើន (សូមមើលលេខ #9)
- ជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោន
- ជនអន្តោប្រវេសន៍ពិសេស ស្ថានភាពអនីតិជន
- ស្ថានភាពមិនមែនអន្តោប្រវេសន៍ U
- អ្នកប្តឹងដោយខ្លួនឯង
- ស្ថានភាពមិនមែនអន្តោប្រវេសន៍ T
- DACA
- TPS (ស្ថានភាពការពារបណ្តោះអាសន្ន)
- អ្នកផ្សេងទៀត (ជនជាតិអាមេរិកអាស៊ី; អ្នកបកប្រែយោធាអាហ្គានីស្ថាន និងអ៊ីរ៉ាក់; អ្នកដាក់ពាក្យសុំកែសម្រួលសញ្ជាតិគុយបា និងហៃទី; ជនជាតិនីការ៉ាហ្គាយ និងជនជាតិអាមេរិកកណ្តាលមួយចំនួននៅក្រោម NACARA; អ្នកដាក់ពាក្យសុំចុះបញ្ជី; អ្នកត្រូវបានដោះលែងសញ្ជាតិសូវៀត និងអាស៊ីអាគ្នេយ៍)។

**7. ខ្ញុំជាអ្នករស់នៅអចិន្ត្រៃយ៍ស្របច្បាប់ (LPR) (នោះគឺខ្ញុំមានប័ណ្ណបៃតង); តើខ្ញុំនៅតែអាចដាក់ពាក្យសុំសញ្ជាតិបន្ទាប់ពីច្បាប់ថ្មីស្តីពីបន្ទុកសេវាសាធារណៈបានទេ បើទោះបីជាខ្ញុំប្រើកម្មវិធីអត្ថប្រយោជន៍សាធារណៈក៏ដោយ?**

បាន។ មិនមានសំណួរ ការពិចារណាសម្រាប់ការប្រើប្រាស់កម្មវិធីសាធារណៈទេ ប្រសិនបើអ្នកជាអ្នករស់នៅអចិន្ត្រៃយ៍ស្របច្បាប់ដែលដាក់ពាក្យសុំសញ្ជាតិ។

**8. តើមានឱកាសណាដែលខ្ញុំអាចត្រូវបាននិរទេសចំពោះការប្រើប្រាស់កម្មវិធីសាធារណៈដែរទេ?**

មិនមានការផ្លាស់ប្តូរបទដ្ឋាននៃការនិរទេសនៅក្នុងច្បាប់ថ្មីក្រៅពីការពង្រីកកម្មវិធីទៅកម្មវិធី Medicaid, SNAP និងកម្មវិធីជំនួយលំនៅដ្ឋានដោយបន្ថែមលើជំនួយជាសាច់ប្រាក់ និងការថែទាំរយៈពេលវែងនោះទេ។ ទោះយ៉ាងណាក៏ដោយរដ្ឋាភិបាលសហព័ន្ធកំពុងពិចារណាធ្វើការផ្លាស់ប្តូរមួយចំនួនចំពោះច្បាប់នេះ។ ប៉ុន្តែសម្រាប់ពេលនេះគ្មានអ្វីផ្លាស់ប្តូរទេ។

**9. ខ្ញុំជាអ្នករស់នៅអចិន្ត្រៃយ៍ស្របច្បាប់ (LPR); តើខ្ញុំមានការព្រួយបារម្ភអំពីបន្ទុកសេវាសាធារណៈនៅពេលដែលខ្ញុំត្រលប់មកវិញពីការធ្វើដំណើរនៅក្រៅសហរដ្ឋអាមេរិកដែរឬទេ?**

ដូចមុនដែរ អ្នករស់នៅអចិន្ត្រៃយ៍ស្របច្បាប់ (LPRs) ត្រូវបានគេណែនាំមិនឱ្យធ្វើដំណើរទៅក្រៅសហរដ្ឋអាមេរិកលើសពី 180 ថ្ងៃឡើយ។ប្រសិនបើអ្នកបាននៅក្រៅសហរដ្ឋអាមេរិកអស់រយៈពេលជាង 180 ថ្ងៃ អ្នកអាចត្រូវបានចាត់ទុកជាអ្នកចំណូលថ្មី ហើយអាចត្រូវទទួលការធ្វើតេអំពីបន្ទុកសេវាសាធារណៈ។ *ប្រសិនបើអ្នកជាអ្នករស់នៅអចិន្ត្រៃយ៍ស្របច្បាប់ សូមកុំធ្វើដំណើរទៅក្រៅសហរដ្ឋអាមេរិកលើសពី 180 ថ្ងៃក្នុងពេលតែមួយ។*

**10. តើខ្ញុំអាចឧបត្ថម្ភសមាជិកគ្រួសាររបស់ខ្ញុំបានទេ ប្រសិនបើខ្ញុំប្រើកម្មវិធីអត្ថប្រយោជន៍សាធារណៈ?**

វាអាស្រ័យ។ ច្បាប់សម្រាប់ការឧបត្ថម្ភមិនមានការផ្លាស់ប្តូរទេ។ អ្នកនៅតែអាចដាក់សំណើសុំនាំសមាជិកគ្រួសាររបស់អ្នកទៅសហរដ្ឋអាមេរិកបាន។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើអ្នកកំពុងប្រើកម្មវិធីអត្ថប្រយោជន៍សាធារណៈ អ្នកប្រហែលជាមិនអាចរៀបចំ "លិខិតបញ្ជាក់ពីការគាំទ្រ" ដើម្បីបង្ហាញថាអ្នកអាចគាំទ្រផ្នែកហិរញ្ញវត្ថុរបស់ពួកគេបានឡើយ។ អ្នកប្រហែលជាត្រូវរកនរណាម្នាក់ផ្សេងទៀត ដើម្បីដាក់ឯកសារបញ្ជាក់ពីការគាំទ្រ។ សូមពិគ្រោះជាមួយមេធាវីដែលទទួលការបណ្តុះបណ្តាលអំពីបន្ទុកសេវាសាធារណៈ ដើម្បីពិនិត្យមើលករណីរបស់អ្នក។

**11. ខ្ញុំគ្មានឯកសារ។ ប្រសិនបើខ្ញុំដាក់ពាក្យសុំកម្មវិធី Medicaid, SNAP ឬកម្មវិធីផ្សេងទៀតសម្រាប់កូនៗរបស់ខ្ញុំ តើពួកគេអាចរាយការណ៍ពីខ្ញុំទៅកាន់ស្ថាប័នអនុវត្តច្បាប់អន្តោប្រវេសន៍ដែរឬទេ?**

ទេ។

មានច្បាប់ដែលចែងថាព័ត៌មានដែលអ្នកចែកចាយនៅពេលអ្នកដាក់ពាក្យសុំកម្មវិធីអត្ថប្រយោជន៍សាធារណៈមិនអាចត្រូវបានប្រើសម្រាប់គោលបំណងអនុវត្តច្បាប់អន្តោប្រវេសន៍ទេ។ ច្បាប់ថ្មីស្ដីពីបន្ទុកសាធារណៈមិនផ្លាស់ប្ដូរករណីនេះទេ។ លើសពីនេះទៀត ប្រសិនបើអ្នកដាក់ពាក្យសុំសម្រាប់កូនអ្នក អ្នកនឹងត្រូវផ្ដល់ព័ត៌មានអំពីស្ថានភាពអន្តោប្រវេសន៍របស់កូនអ្នកប៉ុណ្ណោះ។ ប្រសិនបើអ្នកគ្មានឯកសារ និងដាក់ពាក្យសុំឲ្យកូនអ្នក អ្នកមិនគួរផ្ដល់ព័ត៌មានអំពីស្ថានភាពអន្តោប្រវេសន៍ផ្ទាល់ខ្លួនរបស់អ្នកទេ។ អ្នកអាចនិយាយថា "ខ្ញុំមិនដាក់ពាក្យសុំការធានារ៉ាប់រងសុខភាព ឬ (ប័ណ្ណអាហារ) សម្រាប់ខ្លួនខ្ញុំទេ។"

**សម្រាប់ព័ត៌មានបន្ថែម** អ្នកអាចចូលប្រើឧបករណ៍វាយតម្លៃបន្ទុកសេវាសាធារណៈ ដើម្បីយល់កាន់តែច្បាស់ថាតើស្ថានភាពអន្តោប្រវេសន៍អាចរងផលប៉ះពាល់អត្ថប្រយោជន៍នានា និងពេលណាត្រូវស្វែងរកការប្រឹក្សាផ្នែកច្បាប់។ ឧបករណ៍នេះមានជាភាសាអង់គ្លេសនៅលើគេហទំព័រ៖ KeepYourBenefitsCA.org ឬជាភាសាអេស្ប៉ាញនៅលើគេហទំព័រ៖ TusBeneficiosPublicos.org ។ ឧបករណ៍នេះក៏អាចរកបានតាមរយៈការផ្ញើសារ "អត្ថប្រយោជន៍" (សម្រាប់ភាសាអង់គ្លេស), "Libre" (សម្រាប់ភាសាអេស្ប៉ាញ), "福利" (ភាសាចិន) ឬ "lợiích" (ភាសាវៀតណាម) ទៅកាន់លេខ (**650)376-8006**។